**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ០១៨០/១៥ ក.អ.ជ

ថ្ងៃចន្ទ ១៤កើត ខែមាឃ ឆ្នាំមមី ព.ស. ២៥៥៨

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែកុម្ភៈ គ.ស. ២០១៥

# របាយការណ៍

## វឌ្ឍនភាពការងារប្រចាំខែមករា ឆ្នាំ ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## I. សេចក្តីផ្តើម

ស្ថិរភាពនយោបាយ សេដ្ឋកិច្ច និងសង្គម នៃព្រះរាជាណាចក្រកម្ពុជា គួបផ្សំនឹងលទ្ធផលនៃការអនុវត្ត យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ ដែលបាន និងកំពុងនាំមកនូវកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ជូនដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់នៅទូទាំងប្រទេស ពិសេសតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា បានស្តែងឡើងតាមរយៈសមិទ្ធផលនានាគ្រប់វិស័យនៅទូទាំងប្រទេស បង្កលក្ខណៈឱ្យប្រជាពលរដ្ឋមានល័ក្ខខ័ណ្ឌជីវិតរស់នៅប្រកបដោយសុខដុមរមនា និងសុភមង្គល គួរជាទីមោទនៈ ។ ក្រសួងអភិវឌ្ឍន៍ជនបទ បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ នៅក្នុងបេសកកម្មរបស់រាជរដ្ឋាភិបាល ក្នុងសកម្មភាពអភិវឌ្ឍន៍ជាតិ និងការកាត់បន្ថយភាពក្រីក្រ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចនូវសមិទ្ធផលសំខាន់ៗជាច្រើន ជូនប្រជាពលរដ្ឋទូទាំងប្រទេស តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលជាគ្រឹះដ៏មានសារៈសំខាន់ជួយសម្រាលបាននូវទុក្ខលំបាករបស់ប្រជាជននៅតាមមូលដ្ឋានដោយផ្ទាល់ ។

នៅក្នុងខែមករា ឆ្នាំ ២០១៥ នេះ ក្រសួងសម្រេចបានលទ្ធផលការងារដូចខាងក្រោម ÷

## II. អំពីការងារគ្រប់គ្រងរបស់ក្រសួង

### ១. ការងាររដ្ឋបាល និងបុគ្គលិក

បច្ចុប្បន្នក្រសួងមានមន្ត្រីរាជការក្របខ័ណ្ឌសរុបចំនួន ១.៦៩៧ នាក់ ក្នុងនោះស្រីចំនួន ៣៥៤ នាក់ ។ មន្ត្រីរាជការនៅថ្នាក់កណ្តាលមានចំនួន ៤៩២ នាក់ ស្រីចំនួន ១២៩ នាក់ និងថ្នាក់រាជធានី ខេត្ត ចំនួន ១.២០៥ នាក់ ស្រីចំនួន ២២៥ នាក់ ។ ក្នុងចំណោមនោះ ក្រសួងបានផ្ទេរក្របខ័ណ្ឌចេញចំនួន ០១ នាក់ និងចូលរួមលុបបំបាត់ភាពអសកម្មរបស់មន្ត្រីដោយលុបឈ្មោះចេញពីក្របខ័ណ្ឌ ចំនួន ០១ នាក់។

ចំពោះការងារចរាចរលិខិតស្នាម ក្រសួងបានចេញប្រកាស និងសេចក្តីសម្រេចចំនួន ២៩ ច្បាប់ ចុះលេខលិខិតចេញចំនួន៧២ច្បាប់ ទទួលលិខិតចូលចំនួន ១៣៨ ច្បាប់ និងចេញលិខិតបេសកកម្មចំនួន ៦៨ ច្បាប់ ។



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

**២. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

នៅដើមឆ្នាំ ២០១៥ នេះ ក្រសួងទទួលបាននូវថវិកាសរុបចំនួន ២០៦.៣៦០.០០០.០០០ រៀល ។ សរុបចំណាយខែមករា ឆ្នាំ ២០១៥ របស់ក្រសួងធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៥ សម្រេច ÷

- ចំណាយចរន្តអនុវត្តបានចំនួន ៥.២៣៧.៣៨៣.៣០០ រៀល ស្មើនឹង ៦,០៦%
- ចំណាយមូលធនអនុវត្តបានចំនួន ០ រៀល ស្មើនឹង 0%

**៣. ការងារផែនការ**

- ធ្វើបច្ចុប្បន្នភាពគេហទំព័រក្រសួង
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្លូវជនបទ និងមន្ត្រីរាជការក្រសួង
- ចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយអង្គការអភិវឌ្ឍន៍សហគ្រាសទឹក និង អនាម័យកម្ពុជា (Watershed) អង្គការចីរភាពកម្ពុជា ។

**៤. ការងារអធិការកិច្ច និងសវនកម្ម**

**ក. ការងារអធិការកិច្ច**

- ចូលរួមអង្គប្រជុំបំភ្លឺលើលិខិតរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ស្តីពីការណែនាំឱ្យកែលម្អលើចំណុចខ្វះខាតនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ក្រចេះ ព្រះវិហារ កំពត និង ខេត្តឧត្តរមានជ័យ ។

**ខ. ការងារសវនកម្ម**

- ចុះតាមដានសាកល្បងការអនុវត្តតាមអនុសាសន៍សវនកម្មឆ្នាំ ២០១៤ ដោយប្រើប្រាស់ថវិកា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅខេត្តតាកែវ និងខេត្តកែប ។

## III. សកម្មភាពការងារតាមវិស័យ

**១. ការងារអភិវឌ្ឍន៍ផ្លូវជនបទ**

- ចុះត្រួតពិនិត្យប្រគល់ទទួល វាយតម្លៃ និងបញ្ចប់សុពលភាព ការងារជួសជុល និងសាងសង់ផ្លូវ ក្រាលក្រួសក្រហម ប្រវែង ៣,៥០ គ.ម ស្ពានបេតុងចំនួន ០៣ កន្លែង សរុបប្រវែង ៨៤ ម និងលូគ្រប់ប្រភេទ ចំនួន ១៥ កន្លែង នៅខេត្តកំពង់ធំ
- ចុះត្រួតពិនិត្យប្រគល់ទទួល វាយតម្លៃ និងបញ្ចប់សុពលភាពការងារថែទាំផ្លូវជាលក្ខណៈខួបផ្លូវ ក្រាលក្រួសក្រហមប្រវែង ៤,៥០ គ.ម និងលូគ្រប់ប្រភេទចំនួន ០៥ កន្លែង នៅខេត្តព្រះវិហារ។

**២. ការងារផ្គត់ផ្គង់ទឹកជនបទ**

- សាងសង់អណ្តូងលូបានចំនួន ០៥ អណ្តូង ជូនប្រជាពលរដ្ឋចំនួន ០៨ គ្រួសារ នៅខេត្តស្វាយរៀង
- ស្តារស្រះសហគមន៍បានចំនួន ០១ ស្រះ នៅខេត្តតាកែវ
- សិក្សាទីតាំងអណ្តូងស្នប់ចំនួន ១៧ កន្លែង នៅខេត្តកោះកុង

- ណែនាំបន្ថែមដល់ប្រជាពលរដ្ឋអំពីការប្រើប្រាស់ទឹកដែលមានសុវត្ថិភាព បញ្ហាប៉ះពាល់ នៃការប្រើប្រាស់ទឹកពីប្រភពខាងក្រៅ ការថែទាំ និងការជួសជុលបន្ថែម នៅខេត្តរតនគិរី ។

**៣. ការងារថែទាំសុខភាព និងអនាម័យជនបទ**

- សាងសង់បង្គន់អនាម័យគ្រួសារបានចំនួន ១៨៦ បង្គន់ នៅខេត្តកំពង់ឆ្នាំង

- ចុះតាមដានការអនុវត្តផែនការសកម្មភាពរបស់អ្នកសម្របសម្រួលអនាម័យភូមិ ឃុំ ស្តីពីការលើកកម្ពស់អនាម័យសហគមន៍ និងការត្រៀមបង្ការគ្រោះទឹកជំនន់ នៅខេត្តកំពង់ចាម បាត់ដំបង បន្ទាយមានជ័យ ព្រៃវែង និងខេត្តសៀមរាប

- ចុះតាមដានវគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់អនាម័យសហគមន៍ និងការត្រៀមបង្ការគ្រោះទឹកជំនន់ក្នុង ១១ ឃុំ ចំនួន ១១ វគ្គ នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម

- ចុះពិនិត្យផ្ទៀងផ្ទាត់ការងារសាងសង់បង្គន់អនាម័យរបស់ប្រជាពលរដ្ឋនៅខេត្តពោធិ៍សាត់ ព្រៃវែង កំពត និងខេត្តកំពង់ចាម ។

**៤. ការងារអភិវឌ្ឍន៍សហគមន៍**

- ត្រួតពិនិត្យការងារសន្តិសុខស្បៀង ចំនួន ០១ លើក និងការងារអភិវឌ្ឍន៍ចម្រុះចំនួន ០១ លើក នៅខេត្តកំពង់ស្ពឺ

- ចូលរួមចែកមេគោ ចំនួន ១០ ក្បាល ដល់ ១០ គ្រួសារ ដល់ក្រុមជួយខ្លួនឯង និងបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពយុវជនស្តីពីអាជីវកម្មខ្នាតតូច ចំនួន ៣ វគ្គ មានសិក្ខាកាមចំនួន ១០២ នាក់ ស្រី ៤៨ នាក់ នៅខេត្តស្វាយរៀង ។

**៥. ការងារបណ្តុះបណ្តាល**

ក្រសួងក៏បានបញ្ជូនមន្ត្រីទៅចូលរួម÷

- វគ្គបណ្តុះបណ្តាលក្នុងប្រទេសសរុបចំនួន ៣៧ នាក់ ក្នុងនោះស្រី ០៥ នាក់ និងក្រៅប្រទេសសរុបចំនួន ០២ នាក់ ក្នុងនោះស្រី ០១ នាក់

- សិក្ខាសាលាក្នុងប្រទេសសរុបចំនួន ១១២ នាក់ ក្នុងនោះស្រី ០៦ នាក់ និង

- ទស្សនកិច្ចសិក្សាក្នុងប្រទេសសរុបចំនួន ០១ នាក់ និងក្រៅប្រទេសសរុបចំនួន ០១ នាក់ ។

ជាមួយគ្នានោះដែរ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តព្រៃវែង កំពង់ស្ពឺ តាកែវ កំពង់ចាម បាត់ដំបង ពោធិ៍សាត់ និងខេត្តស្វាយរៀង មានតួនាទីបណ្តុះបណ្តាលនូវមុខជំនាញវិជ្ជាជីវៈជូនដល់ប្រជាពលរដ្ឋក្រីក្រ យុវជនអត់ការងារធ្វើ បោះបង់សាលា កុមារកំព្រា និងជនងាយរងគ្រោះ និងចំណេះដឹងជំនាញមូលដ្ឋានមួយចំនួន ដើម្បីឱ្យពួកគេមានលទ្ធភាពស្វែងរកការងារធ្វើ ឬបង្កើតមុខរបរសម្រាប់បង្កើនប្រាក់ចំណូលក្នុងគ្រួសារ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តបាត់ដំបង បានបញ្ចប់បណ្តុះបណ្តាលកាត់ដេរសម្លៀកបំពាក់ កាត់សក់បុរស និងជួសជុលម៉ាស៊ីនកសិកម្ម

ខ្នាតតូច មានសិក្ខាកាមចូលរួមសរុបចំនួន ៩៥ នាក់ ស្រី ២៤ នាក់ ។ ចំណែកមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តព្រៃវែង ស្វាយរៀង កំពង់ស្ពឺ តាកែវ កំពង់ចាម និងខេត្តកំពត កំពុងផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាលសម្រាប់ឆមាសទី ១ ឆ្នាំ ២០១៥ ។

**៦. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**

គម្រោងឥណទានជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងកម្មវិធីឥណទាន ដែលសហការជាមួយដៃគូ នៅខេត្តកំពង់ចាម ត្បូងឃ្មុំ ពោធិ៍សាត់ កំពត សៀមរាប កោះកុង បាត់ដំបង តាកែវ ស្វាយរៀង ព្រះសីហនុ និងខេត្តបន្ទាយមានជ័យ បានផ្តល់ឥណទានសរុបចំនួន ៤.៩១០.៧២៨.៨៤០ រៀល ស្មើនឹង ១.២២៧.៦៨២,២១ ដុល្លារអាមេរិក ដែលមានគ្រួសារខ្ចីចំនួន ៥.១៣៤ គ្រួសារ នៅភូមិគោលដៅចំនួន ២០៤ ឃុំ ៦៧ ស្រុក ២៥ ។

**តារាងទិន្នន័យឥណទានជនបទតាមខេត្តក្នុងខែមករា ឆ្នាំ ២០១៥**

| ល.រ | ខេត្ត | ប្រាក់ឥណទានកំពុងប្រើប្រាស់ (ដុល្លារ) | ចំនួនអ្នកខ្ចី (នាក់) | ចំនួនភូមិ | ចំនួនឃុំ | ចំនួនស្រុក |
|---|---|---|---|---|---|---|
| ១ | កំពង់ចាម | ៤០២.១១២ | ១.០៧១ | ៨៨៦ | ៤៧ | ១៥ |
| ២ | ត្បូងឃ្មុំ | ១៩០.១៤២,៦០ | ២៦៦ | ១៧០ | ២៣ | ៧ |
| ៣ | ពោធិ៍សាត់ | ១៩៥.២១២,៥០ | ៩៣៦ | ៨៧៧ | ៣៨ | ១៣ |
| ៤ | កំពត | ៧២.៧៧៥ | ៣២០ | ៣០៨ | ១៤ | ៨ |
| ៥ | សៀមរាប | ២១.៨០០ | ១០៥ | ៩៤ | ៤ | ៤ |
| ៦ | កោះកុង | ៨៣.២០៩ | ៤២០ | ២៨៥ | ៨ | ៤ |
| ៧ | បន្ទាយមានជ័យ | ៥៧.៤៤៥ | ៣២២ | ២៥៦ | ៤ | ១ |
| ៨ | បាត់ដំបង | ៤៣.៩២៦,១១ | ១៧១ | ១៣៥ | ៩ | ៥ |
| ៩ | តាកែវ | ៣៩.៣០០ | ១៣១ | ៨៤ | ១១ | ៤ |
| ១០ | ស្វាយរៀង | ១១៦.៧៨៥ | ១.៣៦៧ | ៨៥៥ | ៤៥ | ៥ |
| ១១ | ព្រះសីហនុ | ៤.៩៧៥ | ២៥ | ២១ | ១ | ១ |
| **សរុប** | | **១.២២៧.៦៨២,២១** | **៥.១៣៤** | **៣.៩៧១** | **២០៤** | **៦៧** |

- បូកសរុប និងសម្របសម្រួលគាំទ្រផ្នែកបច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ ដែលមានស្រូវសរុបចំនួន ២០.៥១៣ គ.ក្រ មានសមាជិក១.៣៦៧ នាក់ ស្មើនឹង ២៣៧ ក្រុម នៅខេត្តស្វាយរៀង ។

**៧. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

- ចុះពិនិត្យស្រាវជ្រាវវិវាទរវាងសហគមន៍ជនជាតិដើមភាគតិចពួង នៅភូមិចក់ចារ ឃុំស្រែឈូក និងភូមិពូគង់ ភូមិពូចារ និងភូមិអូរចារ ឃុំស្រែព្រះ ខេត្តមណ្ឌលគិរី

- ចូលរួមប្រជុំពេញអង្គដើម្បីពិនិត្យ និងអនុម័តលើសេចក្ដីព្រាងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិចការ៉ែត នៅភូមិទាក ភូមិទាម និងភូមិអូរចាយ ឃុំសន្តិភាព ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។

**៨. ការងារយេនឌ័រ**

- ចូលរួមកិច្ចប្រជុំសមញ្ញលើកទី ៤១-៤២ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដោយមានការចូលរួមពីអង្គការដៃគូអភិវឌ្ឍន៍នានា និងក្រុមការងារយេនឌ័រនៅតាមបណ្ដាអន្តរក្រសួងស្ថាប័ន ។

## IV. ការអនុវត្តគម្រោង និងកម្មវិធីផ្សេងៗ

**១. កម្មវិធីអភិវឌ្ឍន៍ការតាំងទីលំនៅតាមបណ្ដោយព្រំដែនទិសខាងលិច និងខាងជើង**

គម្រោងអភិវឌ្ឍន៍នៅតាមបណ្ដោយព្រំដែនទិសខាងលិច និងខាងជើង នៃព្រះរាជាណាចក្រកម្ពុជា បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយអគ្គិសនីកម្ពុជា សាងសង់ផ្ទះចំនួន ៣៧ ខ្នង នៅស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ។ ដំណើរការសាងសង់ផ្ទះសម្រេចលើកគ្រោងចំនួន ២៤ ខ្នង រួមមាន÷

| | |
|---|---|
| - វាយជញ្ជាំង | បានចំនួន ៥ ខ្នង |
| - វាយរបារ និងដែរណែង | បានចំនួន ៤ ខ្នង |
| - វាយដែរណែង | បានចំនួន ៥ ខ្នង |
| - វាយផ្ទោង | បានចំនួន ៤ ខ្នង |
| - លើកគ្រោង | បានចំនួន ៦ ខ្នង |

**២. កម្មវិធីទឹកស្អាត និងអនាម័យ ក្រោមហិរញ្ញប្បទានរបស់អង្គការយូនីសេហ្វ (UNICEF)**

អង្គការ UNICEF កំពុងសហការជាមួយនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ក្នុងវិស័យទឹកស្អាត និងអនាម័យ ដែលមានគោលដៅលើកស្ទួយសុខមាលភាពប្រជាពលរដ្ឋនៅតាមតំបន់ជនបទ នៅក្នុងខេត្តចំនួន ១០ គឺ ខេត្តស្ទឹងត្រែង កំពង់ចាម ឧត្តរមានជ័យ កំពង់ឆ្នាំង ក្រចេះ កណ្ដាល កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង និងខេត្តកំពង់ធំ ។ ក្នុងខែមករា ឆ្នាំ ២០១៥ គម្រោងសម្រេចបាន÷

- រៀបចំវគ្គបណ្ដុះបណ្ដាលដល់ជនបង្គោលឃុំ ភូមិ ស្ដីពីការធ្វើតេស្តគុណភាពទឹក មានអ្នកចូលរួមចំនួន ៤២ នាក់ និងផ្ដល់ថ្នាំលាបដល់សាលាបឋមសិក្សាដែលបានទទួលអាងត្រង់ទឹកភ្លៀង ក្នុងការលាបពណ៌អាង និងគូសរូបភាពជាសារក្នុងការអប់រំប្រើប្រាស់ទឹកសុវត្ថិភាព និងអនុវត្តន៍អនាម័យដល់សិស្ស ចំនួន ១០ សាលា នៅខេត្តព្រៃវែង

- ផ្ដល់សម្ភារៈរួមមាន ប៊ីដុងទឹក ៨៥០ ប៊ីដុង ធុងទឹក ៧០០ ធុង ថ្នាំបន្សុទ្ធទឹកបន្ទុះ ៨១ ៦០០ បន្ទុះ ថ្នាំបន្សុទ្ធទឹកកញ្ចប់ ៦៩ ១២០ កញ្ចប់ សាប៊ូដុំ ១.៦៥០ ដុំ ផ្ទាំងរូបភាពអប់រំអនាម័យ ៤ ០០០ ផ្ទាំង និងធុងចម្រោះសេរ៉ាមិក ៩០ ធុង នៅខេត្តបន្ទាយមានជ័យ

- ផ្តល់សម្ភារៈសម្រាប់បន្សុទ្ធទឹកប្រភេទគ្រាប់ Aquatab ចំនួន ២០ កេះ និងម្សៅ Pur ចំនួន ១៥០ ប្រអប់ និងសាប៊ូលាងសម្អាតដៃ ៥០០ ដុំ នៅខេត្តស្ទឹងត្រែង ។

### ៣. គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យជនបទ ដំណាក់កាលទី ២

គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យជនបទ ដំណាក់កាលទី ២ (Rural Water Supply and Sanitation Sector Project - RWSSP2) សម្រាប់អនុវត្តរយៈពេល ៥ ឆ្នាំ (២០១០-២០១៥) មានថវិកាចំនួន ២៥,៨ លានដុល្លារ (ថវិការាជរដ្ឋាភិបាល ១,៨ លានដុល្លារ ជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ២១ លានដុល្លារ និងការចូលរួមរបស់អ្នកទទួលផល ៣ លានដុល្លារ) ក្នុងខេត្តគោលដៅចំនួន ៦ គឺខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ ។ ក្នុងខែមករា ឆ្នាំ ២០១៥ គម្រោងសម្រេចបាន÷

- សាងសង់បង្គន់អនាម័យតាមគ្រួសារបានចំនួន ១៨៦ បង្គន់ និងពង្រឹងក្រុមប្រើប្រាស់ទឹក និងអនាម័យដោយជំរុញឱ្យធ្វើរបងអណ្តូងទឹក និងការសន្សំប្រាក់សម្រាប់ជួសជុល នៅខេត្តកំពង់ឆ្នាំង
- រៀបចំវគ្គបណ្តុះបណ្តាលអំពីផែនការសុវត្ថិភាពទឹកស្អាត មានសមាជិកចូលរួមចំនួន ៦៧១ នាក់ ស្រី ៣៩២ នាក់ នៅខេត្តបន្ទាយមានជ័យ ។

### ៤. គម្រោងកែលម្អផ្លូវជនបទ

គម្រោងកែលម្អផ្លូវជនបទ (Rural Road Improvement Project - RRIP) រយៈពេល ៥ ឆ្នាំ (២០១១-២០១៦) មានថវិកា ៦៧ លានដុល្លារ (ក្នុងនោះហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល ៧,២៥ លានដុល្លារ ប្រាក់កម្ចីធនាគារអភិវឌ្ឍន៍អាស៊ី ៣៥ លានដុល្លារ ប្រាក់កម្ចីធនាគារ Keximbank របស់សាធារណរដ្ឋកូរ៉េ ២១ លានដុល្លារ និងជំនួយឥតសំណងរបស់មូលនិធិ NDF ៥,៤ លានដុល្លារ) សម្រាប់កែលម្អផ្លូវជនបទប្រវែង ៥០៥,៤០ គ.ម ដោយក្រាលកៅស៊ូប្រភេទពីរជាន់ (DBST) ក្នុងខេត្តចំនួន ៧ គឺខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ។ ក្នុងខែមករា ឆ្នាំ ២០១៥ នេះ គម្រោងដំណើរការសាងសង់ផ្លូវក្រាលកៅស៊ូនៅលើផ្លូវចំនួន ២២ ខ្សែ សរុបប្រវែង ៥៣៧,៤៥៤ គ.ម និងស្ពាន ៥ កន្លែង ក្នុងនោះគម្រោងសម្រេចបាន ÷

#### ក. ខេត្តពោធិ៍សាត់

- ខ្សែផ្លូវសំរោង-តាលោ ប្រវែង ១៨,៧៣៨ គ.ម ក្នុងនោះកៀរសម្អាត កែសម្រួលតួផ្លូវ លើកស្រទាប់ទ្រនាប់គ្រឹះ លើកស្រទាប់គ្រឹះ ក្រាលស្រទាប់ថ្មម៉ិច កៅស៊ូទ្រនាប់ និងក្រាលស្រទាប់ទី ១ បានសម្រេច ១០០%
- ខ្សែផ្លូវបឹងខ្នា-តាលោប្រវែង ១៩,៤២៥ គ.ម ក្នុងនោះកៀរសម្អាត កែសម្រួលតួផ្លូវ និងលើកស្រទាប់ទ្រនាប់គ្រឹះ លើកស្រទាប់គ្រឹះ ក្រាលស្រទាប់គ្រឹះថ្មម៉ិច ក្រាលកៅស៊ូទ្រនាប់ប្រវែង សម្រេច ១០០% ក្រាលស្រទាប់ទី ១ ប្រវែង ១៣,៥៣ គ.ម និងក្រាលស្រទាប់ទី ២ ប្រវែង ១,៥៣ គ.ម
- ខ្សែផ្លូវត្រពាំងជង-ផ្ទះរុង ប្រវែង ២២,៣០៤ គ.ម ក្នុងនោះកៀរសម្អាត និងកែសម្រួលតួផ្លូវ

លើកស្រទាប់ទ្រនាប់គ្រឹះ **និង**លើកស្រទាប់គ្រឹះ ក្រាលស្រទាប់ថ្មម៉ិច ក្រាលកៅស៊ូទ្រនាប់ សម្រេច ១០០% និងក្រាលស្រទាប់ទី ១ ប្រវែង ១៣ គ.ម

- ខ្សែផ្លូវពីបឹងខ្នារ-មេទឹក ប្រវែង ៩,៧៥៤ គ.ម ក្នុងនោះ កៀរសម្អាត កែសម្រួលតួផ្លូវ លើកស្រទាប់ទ្រនាប់គ្រឹះ និងលើកស្រទាប់គ្រឹះ សម្រេច ១០០% និងក្រាលស្រទាប់ថ្មម៉ិច ប្រវែង ៣,៨៧ គ.ម

- ខ្សែផ្លូវពីបឹងកន្ទួត-កំពង់ពោធិ៍ ប្រវែង ៨,៧០៨ គ.ម ក្នុងនោះ កៀរសម្អាត កែសម្រួលតួផ្លូវ លើកស្រទាប់ទ្រនាប់គ្រឹះ សម្រេច ១០០% និងលើកស្រទាប់គ្រឹះ ប្រវែង ២ គ.ម ។

**ខ. ខេត្តបាត់ដំបង**

- ខ្សែផ្លូវព្រៃស្វាយ-ព្រៃត្រឡាច-ឫស្សីក្រាំងប្រវែង ២៤,៧១៦ គ.ម សម្រេច ១០០%

- ខ្សែផ្លូវពីផ្លូវជាតិលេខ ៥-ព្រែកជីក-ចុងធំរ ប្រវែង ២៣,៦៣១ គ.ម ក្នុងនោះ ឈូសឆាយ និងកៀរសម្អាត លើកតួផ្លូវ ស្រទាប់ទ្រនាប់គ្រឹះ លើកទ្រនាប់គ្រឹះ ក្រាលស្រទាប់ថ្មម៉ិច ក្រាលកៅស៊ូទ្រនាប់ សម្រេច ១០០% ក្រាលស្រទាប់ទី ១ ប្រវែង ១៧,៣៥ គ.ម និងក្រាលស្រទាប់ទី ២ ប្រវែង ៧,៧០ គ.ម

- ខ្សែផ្លូវពីជ្រៃ-តាលាស់-កកោះ ប្រវែង ២៣,៩០ ក្នុងនោះ កៀរសម្អាត និងកែសម្រួលតួផ្លូវ លើកតួផ្លូវ ស្រទាប់ទ្រនាប់គ្រឹះ និងលើកទ្រនាប់គ្រឹះ សម្រេច ១០០% ក្រាលស្រទាប់ថ្មម៉ិច ប្រវែង ១៨,៧០ គ.ម ក្រាលកៅស៊ូទ្រនាប់ ប្រវែង ៣,៧០ គ.ម និងក្រាលស្រទាប់ទី ១ ប្រវែង ៣,៧០ គ.ម។

**គ. ខេត្តកំពង់ស្ពឺ**

- ខ្សែផ្លូវផ្សារត្រពាំងក្រឡឹង-បាំងកាសី ប្រវែង ៤៥,៤៥ គ.ម រួមមាន លូមូលចំនួន ៣៦ កន្លែង លូប្រអប់ចំនួន ៣ កន្លែង និងទ្វារទឹកចំនួន ២ កន្លែង សម្រេច ១០០%

- ខ្សែផ្លូវគីរីរស្មី-ដកពរ ប្រវែង ២៤,៤១៧ គ.ម រួមមាន លូមូល ១៣ កន្លែង សម្រេច ១០០% ។

**ឃ. ខេត្តកំពង់ឆ្នាំង**

- ខ្សែផ្លូវផ្សារត្រាច-វត្តព្រះធាតុ ប្រវែង ៣៤,៩៧៣ គ.ម សម្រេច ១០០%

- ខ្សែផ្លូវផ្សារពង្រ-រ៉ាក្រាំងស្គារ ប្រវែង ២៥,២៣៨ គ.ម រួមមាន លូមូល ០៦ កន្លែង សម្រេច ១០០%

- ខ្សែផ្លូវស្ពានពោធិ៍-រ៉ាមាននក ប្រវែង ១២,៣៦៤ គ.ម រួមមាន លូមូល ០៦ កន្លែង សម្រេច ១០០% ។

**ង. ខេត្តត្បូងឃ្មុំ**

- ខ្សែផ្លូវជើងឡង-អូររាំងឪ ប្រវែង ២៩,៤០ គ.ម រួមមាន លូមូល ចំនួន ២២ កន្លែង និងលូប្រអប់ចំនួន ២ កន្លែង សម្រេច ១០០%

- ខ្សែផ្លូវប៉ើស ២-កុលលើ ប្រវែង ២១,២០៦ គ.ម រួមមាន លូមូល ៩ កន្លែង លូប្រអប់ ១ កន្លែង និងស្ពាន ១ កន្លែង សម្រេច ១០០%

- ខ្សែផ្លូវមេមត់-កញ្ជាសប្រវែង ១៧,២៦៥ គ.ម រួមមាន លូមូល ៨ កន្លែង សម្រេច ១០០%

- ខ្សែផ្លូវពងទឹក-វត្តឈូក ប្រវែង ១៥,០៦ គ.ម ក្នុងនោះ ឈូសឆាយ និងកៀរសម្អាត លើកតួផ្លូវ ស្រទាប់ទ្រនាប់គ្រឹះ និងលើកស្រទាប់គ្រឹះ ប្រវែង ១២,៥៤ គ.ម ក្រាលស្រទាប់ថ្មម៉ិច ប្រវែង ១២ គ.ម ស្រោច កៅស៊ូទ្រនាប់ ប្រវែង ១០,៤០ គ.ម និងក្រាលស្រទាប់ទី ១ ប្រវែង ១០,៣០ គ.ម ។

**ច. ខេត្តកំពង់ចាម**

- ខ្សែផ្លូវហាន់ជ័យ-ស្ទឹងត្រង់ ប្រវែង ៩,៩៥៩ គ.ម សម្រេច ១០០%

- ខ្សែផ្លូវផ្សារផ្អាវ-គ្រប់ ប្រវែង ១៦,៧៣ គ.ម សម្រេច ១០០% ។

**ឆ. ខេត្តកំពង់ធំ**

- ខ្សែផ្លូវប្រាសាទសំបូរ-សណ្តាន់ ប្រវែង ៦៥,៩៨៧ គ.ម សម្រេច ១០០% ។

**ជ. ខេត្តសៀមរាប**

- ខ្សែផ្លូវលាងដៃ-ស្វាយស ប្រវែង ៤៦,២២៤ គ.ម រួមមាន លូមូលចំនួន ២៨ កន្លែង លូប្រអប់ ចំនួន ៤ កន្លែង សម្រេច ១០០%

- ខ្សែផ្លូវពួក-អង្គរជុំ ប្រវែង ២៩,៥២៣ គ.ម រួមមាន លូមូល ១៦ កន្លែង សម្រេច ១០០%។

**៥. កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ធនាគារអភិវឌ្ឍន៍អាស៊ី ADB បានផ្តល់ជំនួយបច្ចេកទេសសម្រាប់ការអនុវត្តកម្មវិធីកែទម្រង់ការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management for Rural Development Projects - PFMRP) ដល់ក្រសួងចំនួន ០៤ រួមមានក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងអាជ្ញាធរសវនកម្មជាតិ ដោយមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នក សម្របសម្រួល ។ គម្រោងនេះមានរយៈពេល ០៣ ឆ្នាំ (២០១១-២០១៤) ដើម្បីរៀបចំបទដ្ឋានគតិយុត្តសម្រាប់ កែលំអកិច្ចការរៀបចំថវិកា ហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្មសាធារណៈ។ ក្នុងខែមករា ឆ្នាំ ២០១៥ គម្រោង សម្រេច÷

- សម្រេចការរៀបចំថវិកាកម្មវិធីពេញលេញ និងបង្កើតអោយមានអង្គភាពថវិកានៅក្នុងក្រសួង

- ចូលរួមវគ្គបណ្តុះបណ្តាលការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្តីពីការតាមដានត្រួតពិនិត្យ និង វាយតម្លៃដោយផ្អែកលើលទ្ធផល

- ចូលរួមវគ្គបណ្តុះបណ្តាលការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីបទពិសោធន៍ ប្រទេសចិន នៅទីក្រុងសៀងហៃ ប្រទេសចិន ។

**៦. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ដំណាក់កាលទី ៣**

គម្រោងសហហិរញ្ញប្បទានឥតសំណងរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KFW មានទឹកប្រាក់ចំនួន ៤ លានអឺរ៉ូ សម្រាប់កម្មវិធីកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ដំណាក់កាលទី ៣ (Rural

Roads Improvement Project III - RIP-III) ។ ដោយឡែក រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមប្រាក់បដិភាគចំនួន ៦,៦ លានដុល្លារអាមេរិក សម្រាប់ការងារថែទាំផ្លូវរយៈពេល ៣ ឆ្នាំ (២០១៥-២០១៧) និងចំនួន ០,៤ លានអឺរ៉ូ សម្រាប់ការងារសាងសង់នៅក្នុងខេត្តចំនួន ០៨ គឺខេត្តកំពង់ធំ កំពង់ចាម កំពង់ស្ពឺ ក្រចេះ ព្រៃវែង សៀមរាប ត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង ។ ក្នុងខែមករា ឆ្នាំ ២០១៥ គម្រោងសម្រេចបាន ÷

- បាន និងកំពុងធ្វើការសាងសង់ផ្លូវថ្មីសរុប ប្រវែង ៣៩,៤០៩ គ.ម
- បាន និងកំពុងធ្វើការសាងសង់ផ្សារចំនួន ០២ កន្លែង ។

**៧. គម្រោងឥណទានខ្នាតតូច**

នៅចុងឆ្នាំ ២០០៩ និងដើមឆ្នាំ ២០១០ គម្រោងឥណទានខ្នាតតូចដែលគាំទ្រដោយវិទ្យាស្ថានសេដ្ឋកិច្ចជនបទកូរ៉េ (Korea Rural Economic Institute - KREI) បានផ្ដល់ថវិកាដល់ក្រសួងអភិវឌ្ឍន៍ជនបទចំនួន ៨៦.៥០៤,៦៨ ដុល្លារអាមេរិក សម្រាប់ជាមូលនិធិឥណទានបង្វិល ។ ក្នុងខែមករា ឆ្នាំ ២០១៥ នេះ គម្រោងបានផ្ដល់ឥណទានសរុបចំនួន ៤៩៧.៧១៥.៤០០ រៀល ស្មើនឹង ១២៤.៤២៨,៨៥ ដុល្លារ ដោយមានអ្នកខ្ចីចំនួន ៣៣៨ នាក់ នៅក្នុងភូមិគោលដៅចំនួន ០៩ ភូមិ ស្ថិតក្នុងស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ និងស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ បច្ចុប្បន្ន គម្រោងមានថវិកាសរុបចំនួន ៦២៩.៤៨០.៣២៣,០៥ រៀល ស្មើនឹង ១៥៧.៣៧០,០៨ ដុល្លារ ។

**៨. គម្រោងស្តារឡើងវិញបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តខូចខាតដោយគ្រោះទឹកជំនន់ឆ្នាំ ២០១៣**

គម្រោងស្តារឡើងវិញបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តខូចខាតដោយទឹកជំនន់ឆ្នាំ ២០១៣ ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចំនួន ២២ លានដុល្លារ និងជំនួយឥតសំណងរបស់ AUSAID ចំនួន ៣ លានដុល្លារ សម្រាប់ជួសជុលឡើងវិញផ្លូវជនបទចំនួន ២៥ ខ្សែ ប្រវែង សរុប ២៥៦,៦ គ.ម នៅក្នុងខេត្តគោលដៅចំនួន ៦ គឺខេត្តត្បូងឃ្មុំ កំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ និងខេត្តបាត់ដំបង ។ ក្នុងខែមករា ឆ្នាំ ២០១៥ គម្រោងសម្រេច ÷

**ក. ខេត្តត្បូងឃ្មុំ**

- ខ្សែផ្លូវពីភូមិ ៣ ទៅស្ទឹងគគីរ ប្រវែង ៣,៥ គ.ម សម្រេច ១០០%
- ខ្សែផ្លូវពីស្ទឹងគគីរ ទៅបារាយណ៍ ប្រវែង ៤,៣ គ.ម និងលូមូល ០១ កន្លែង សម្រេច ១០០%
- ខ្សែផ្លូវពីទន្លេបិទ ទៅទួលខ្សាច់ ប្រវែង ៤,៣ គ.ម និងលូមូល ០១ កន្លែង សម្រេច ១០០%
- ខ្សែផ្លូវពីថ្មពេជ្រ ទៅបឹងព្រួល ប្រវែង ៥,៦ គ.ម និងលូមូល ០១ កន្លែង សម្រេច ១០០%
- ខ្សែផ្លូវពីព្រែកជីក ទៅអន្លង់ពោង ប្រវែង ៤,៥ គ.ម លូមូល ០១ កន្លែង និងលូប្រអប់ ០១ កន្លែង សម្រេច ១០០% ។

**ខ. ខេត្តកំពង់ចាម**

- ខ្សែផ្លូវពីកោះសូទិន ទៅកោះថ្មី ប្រវែង ៦,៧ គ.ម និងលូមូល ០២ កន្លែង សម្រេច ១០០%
- ខ្សែផ្លូវពីមហាលាភ ទៅជ្រោយសសិត ប្រវែង ៤,៥ គ.ម និងលូមូល ០១ កន្លែង សម្រេច

១០០%។

**គ. ខេត្តកំពង់ធំ**

- ខ្សែផ្លូវពីឈើទាល ទៅកូនក្អែក ប្រវែង ១៤,៥ គ.ម និងលូមូល ០២ សម្រេច ១០០%។

**ឃ. ខេត្តសៀមរាប**

- ខ្សែផ្លូវពីស្រែណូយ ទៅប្រាសាទ ប្រវែង ៣៣,៣០ គ.ម លូមូល ០៥ កន្លែង និងលូប្រអប់ ០១ កន្លែង សម្រេច ១០០%។

**ង. ខេត្តបន្ទាយមានជ័យ**

- ខ្សែផ្លូវពីផ្លូវជាតិលេខ ៥ ទៅចង្ហារ ប្រវែង ១១ គ.ម លូមូល ០៣ កន្លែង និងលូប្រអប់ ០១ កន្លែង សម្រេច ១០០%
- ជួសជុលលូប្រអប់ ០១ កន្លែង នៅផ្លូវជាតិលេខ៥៦ ទៅតាវ៉ង សម្រេច ១០០%។

**ច. ខេត្តបាត់ដំបង**

- ខ្សែផ្លូវពីបាដាក ទៅអង្គត់ផ្លុង ប្រវែង ២២,៥ គ.ម និងលូមូល ០៣ កន្លែង សម្រេច ១០០%។

## V. សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេលមួយខែកន្លងមកនេះ ក្រសួងអភិវឌ្ឍន៍ជនបទ បានខិតខំអនុវត្តនូវតួនាទីរបស់ខ្លួន យ៉ាងសកម្ម និងជំនះរាល់ឧបសគ្គ ដោយសម្រេចបាននូវសមិទ្ធផលការងារយ៉ាងច្រើន ដើម្បីបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ជាមួយសមិទ្ធផលការងារទាំងនេះ ក្រសួងក៏នៅមានការងារជាច្រើនទៀត ដែលត្រូវបំពេញ ដើម្បីសម្រេចគោលដៅជាសារវន្តរបស់ខ្លួន ដោយត្រូវបន្តខិតខំសហការជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន ដើម្បីសម្រេចបានជោគជ័យនូវការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ ។

**រដ្ឋមន្ត្រី**

**ជា សុផារ៉ា**

<u>**ចម្លងជូន**</u> :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មការទី ៣ នៃរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ក្រសួងសុខាភិបាល
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងបរិស្ថាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី
- ថ្នាក់ដឹកនាំក្រសួង អ.ជ.ប

  "*__ដើម្បីជូនជ្រាប__*"

- ឯកសារ-កាលប្បវត្តិ